New Year's Issue
2020

# Living the LOTUS

## Buddhism in Everyday Life

New Year's Message

## <ភាពធម្មតា(សាកសួរជានិច្ចជាកាល)>

ព្រះសង្ឃនីវ៉ាណូ និជិកុ
ព្រះប្រធានរីស្សូកូសេកៃ




### គឺ តាំងពីWCRPកកើតឡើងមានរយៈពេល៥០ឆ្នាំហើយ ពេលរំលឹកឃើញឡើងវិញដល់សេចក្ដីប្រាថ្នារបស់ព្រះស្ថាបនិកកៃសូសាម៉ានាំឱ្យយើងរំភើបចិត្តជាខ្លាំង

នេះជាបុណ្យចូលឆ្នាំថ្មីលើកទី១ហើយ តាំងពី「សកររាជរ៉េយវ៉ា」 ចាប់ផ្ដើមមក។អាត្មាភាពយល់ថាយើងម្នាក់ៗច្បាស់ជាមានសេចក្ដីសង្ឃឹមចំពោះអ្វីមួយនៅក្នុងចិត្តគ្រប់ៗគ្នាមិនខានឡើយ។ កាលពីឆ្នាំមុន ប្រទេសជប៉ុនមានគ្រោះធម្មជាតិជាបន្តបន្ទាប់ដូចជាខ្យល់ព្យុះលេខ១៥ ខ្យល់ព្យុះលេខ១៩ជាដើមដែលធ្វើឱ្យមនុស្សជាច្រើនរងគ្រោះ។អ្នកខ្លះទៅក៏មានគ្រោះបាក់បែកគេហដ្ឋាន អ្នកខ្លះទៀតទៅក៏ខូចខាតផលដំណាំដាំដុះ អ្នកខ្លះទៀតទៅក៏ជួបការដាច់ទឹកដាច់ភ្លើងហើយរស់នៅក្នុងជីវភាពលំបាកលំបិន ហើយអ្នកដែលមិនទាន់អាចស្ដារជីវភាពឱ្យមកជាធម្មតាឡើងវិញបាននៅឡើយក៏មានច្រើន។ខ្ញុំព្រះករុណាអាត្មាភាពសូមចូលរួមរំលែកទុក្ខហើយនិងសូមចូលរួមរំលែកសេចក្ដីលំបាករបស់អ្នកទាំងអស់ផង។

ប្រទេសជប៉ុនជាប្រទេសដែលសំបូរទៅដោយគ្រោះធម្មជាតិ។យើងម្នាក់ៗត្រូវតែយកបទពិសោធន៍ដែលបានឆ្លងកាត់មកហើយមកប្រើការប្រកបដោយប្រសិទ្ធភាពដើម្បីត្រៀមនៅពេលដែលមានអាសន្នកើតឡើងទៀតដូចជាត្រូវត្រៀមបង្ការនូវរបស់របរសម្រាប់ការពារគ្រោះអាសន្ន ឬឆែកមើលពីកម្រិតគ្រោះថ្នាក់នៅទីកន្លែងដែលរស់នៅពោលគឺជួយខ្លួនឯង និង ជួយគ្នាទៅវិញទៅមកដូចជាជួយគ្រួសារខ្លួនឬអ្នកដែលរស់នៅជិតខាងខ្លួនហើយបន្តឱ្យការងារជួយខ្លួនឯងនិងជួយគ្នាទៅវិញទៅមកនេះទៅជាទម្លាប់ដើម្បីធ្វើយ៉ាងណាឱ្យការរងគ្រោះបន្ទាប់មកមានតូចបំផុត។ ជាពិសេសគ្រោះមហន្តរាយធម្មជាតិថ្មីៗនេះទទួលឥទ្ធិពលពីកម្ដៅសីតុណ្ហភាពផែនដី

# New Year's Message 2020

លំដាប់ពិភពលោក ដូច្នេះកំរឹតនៃមហន្តរាយកាន់តែឡើងធំទៅៗ ហើយការប្រែប្រួលនៃអាកាសធាតុបែបនេះគេអាចសន្និដ្ឋានខ្ពស់បានថាអាចបណ្ដាលមកពីសកម្មភាពរបស់មនុស្សតែម្ដង។នៅក្នុងភាពសម្បូរសប្បាយប្រទេសជប៉ុនបានផលិតរបស់ច្រើនជ្រុល ប្រើរបស់ច្រើនជ្រុល និងចោលរបស់ក៏ច្រើនជ្រុលដែរ។យើងឈានចូលមកដល់ចំណុចដែលត្រូវតែប្ដូរទស្សនៈនិងគំនិតហើយ។

ឆ្នាំមុននៅឯប្រទេសអាល្លឺម៉ង់មានប្រារព្ធការប្រជុំ WCRP （ការប្រជុំសន្តិភាពនៃអ្នកសាសនាពិភពលោក） ដែលជាមហាសន្និបាតពិភពលោកលើកទី១០។ហើយឆ្នាំនេះក៏ជាគម្រប់ខួប៥០ឆ្នាំនៃ WCRP ដែរ។ការបង្កើតនិងការអភិវឌ្ឍ WCRPឱ្យបានលូតលាស់រីកចម្រើន គឺជាសេចក្ដីប្រាថ្នាដ៏មុះមត់របស់ព្រះស្ថាបនិកកៃស្វសាម៉ា។ដូច្នេះរយៈកាលកន្លះសតវត្សដែល WCRPប្រព្រឹត្តទៅបាននេះពិតជាធ្វើឱ្យខ្ញុំព្រះករុណាអាត្មាភាពមានសេចក្ដីរំភើបយ៉ាងជ្រាលជ្រៅ។

មហាសន្និបាតលើកនេះមានការទទួលនិងសហាប្រត្តិបត្តការពីក្រសួងការបរទេសអាល្លឺម៉ង់ ។មហាសន្និបាតនេះមិនត្រឹមតែរឹតចំណងមិត្តភាពរវាងអ្នកសាសនាតែប៉ុណ្ណោះទេក៏ប៉ុន្តែពីមួយឆ្នាំទៅមួយឆ្នាំចំណងមិត្តភាពរវាងរដ្ឋាភិបាលនៃប្រទេសនីមួយៗ និងអង្គការសហប្រជាជាតិក៏បានឡើងកាន់តែរឹងមាំទៅៗហើយលាតសន្ធឹងកាន់តែទូលំទូលាយទៅផងដែរ។ព្រលឹងរបស់កៃស្វសាម៉ានិងរៀមច្បងដទៃទៀតដ៏ច្រើនច្បាស់ជាត្រេកអរមិនខានឡើយ។

នៅក្នុងកម្លុងពេលដែលគេប្រារព្ធមហាសន្និបាតនោះសមាជិកនៃរីហ្សូកូសេកៃដែលជាបថមមានដៃសេដូ(ព្រះវិហារធំ)និងគ្រប់ព្រះវិហារទូទាំងប្រទេស បាននាំគ្នាបួងសួងព្រះពុទ្ធជាម្ចាស់ឱ្យលោកជួយខ្ញុំព្រះករុណាអាត្មាភាព។ខ្លួនខ្ញុំព្រះករុណាអាត្មាផ្ទាល់បានចូលរួមរួមក្នុងមហាសន្និបាតទាំងអារម្មណ៍ដឹងគុណចំពោះទឹកចិត្តដ៏ប្រសើររបស់អ្នកទាំងអស់គ្នាដែរ។



ជាការពិតណាស់ដើម្បីឱ្យសន្តិភាពអាចកើតមានឡើងបានទាល់តែមានការជជែកប្ដូរយោបល់គ្នាក្នុងខ្នាតអន្តរជាតិហើយលើសពីនេះទៅទៀតបែបឯកទេសផងដែរ។ក៏ប៉ុន្តែជាមូលដ្ឋានគឺតែងតែធ្វើឱ្យមានសន្តិភាពនៅក្នុងប្រទេសនីមួយៗនិងតំបន់ព្រមទាំងនៅក្នុងគ្រួសារនីមួយៗសិន។ដំបូងឡើងត្រូវតែឱ្យមានសេចក្ដីសុខនៅក្នុងគ្រួសារដោយសមាជិគ្រួសារម្នាក់ៗមានសេចក្ដីសុខក្នុងចិត្តយោលទៅតាមជំនឿទៅលើសាសនានិងការចិញ្ចឹមចិត្តមនុស្សធម៌នៅក្នុងខ្លួន។យើងម្នាក់ៗតែងតែបញ្ជាក់គ្នាទៅវិញទៅមកជាថ្មីម្ដងថាជីវភាពដែលមានជំនឿទៅលើសាសនានាំយើងទៅរកសន្តិភាព។

លើសពីនេះទៅទៀតឆ្នាំនេះ នៅខែសីហា កីឡាអូឡាំពីកនឹងប្រារព្ធឡើងនៅតូក្យូជាលើកទី២ហើយនឹងមានជនបរទេសជាច្រើនចូលមកប្រទេសជប៉ុន។ក្នុងមួយឆ្នាំៗជនបរទេសដែលមកលេងជប៉ុនមានចំនួនពី៣០០០ម៉ឺនទៅ៤០០០ម៉ឺននាក់។ដូច្នេះដើម្បីនឹង ឱ្យគេស្គាល់ពីវិចិត្រភាពនិងភាពកក់ក្ដៅរបស់ជប៉ុន,យើងទាំងអស់គ្នាជាសមាជិកនៃរីហ្សូកូសេកៃនឹងចូលរួមចំណែកដោយទទួលគេដោយមុខញញឹម ទន់ភ្លន់ និងកក់ក្ដៅ។

> កកើតឡើងមានរយៈពេល៥០ឆ្នាំហើយ កន្លែងដែលយើងដេកដើរហើរអង្គុយទាំងអស់នោះហើយគឺ＜ជាទីកន្លែងប្រត្តិបត្ត＞ហើយការងារធំតូចនានាដែលយើងធ្វើព្រឹកល្ងាចនោះគឺជាមាគ៌ាព្រះពុទ្ធ

បន្ទាប់ទៅនេះខ្ញុំព្រះករុណាអាត្មាភាពសូមបង្ហាញពីទិសដៅនៃឆ្នាំ២០២០របស់យើងដូចតទៅនេះ។

ធម្មជាតិនិងលោកយើងនេះដើរទៅមុខប្រកបទៅដោយការឆ្នៃប្រឌិតនិងការប្រែប្រួលផ្លាស់ប្ដូរជានិច្ចគ្មានឈប់ទ្រឹងមួយដង្ហើមឡើយ។ហើយយើងម្នាក់ៗក៏ដូច្នេះដែរមិនត្រូវឈប់ស្ងៀមទ្រឹងឡើយទោះជាប្រឈមនឹងអ្វីក៏ដោយត្រូវតែខិតខំដោះស្រាយដោយទឹកចិត្តថ្មីស្រទ្បាងស្រស់ស្រាយជានិច្ចជាកាលដូចធម្មជាតិដែរ។

ឆ្នាំនេះរីហ្សូកូសេកៃយើងមានអាយុគម្រប់៨២ឆ្នាំហើយ។បាតគ្រឹះដ៏រឹងមាំដែលជាប់គង់វង់រហូតដល់មានថ្ងៃនេះកសាងបានមកដោយសារតែការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពមិនស្គាល់ថ្ងៃមិនស្គាល់យប់នៃព្រះស្ថាបនិកកៃស្វសាម៉ា,វ៉ាគីស្វសាម៉ា,រៀមច្បងថ្នាក់ដឹកនាំនិងពុទ្ធបរិស័ទទាំងឡាយនោះឯង។

យើងទាំងឡាយនឹងប្រត្តិបត្តនូវស្មារតី ＜ទីនេះគឺជាទីកន្លែងប្រត្តិបត្ត＞ ដើម្បីសងគុណលោកអ្នកមានគុណទាំងនោះវិញ។

ដើម្បីឱ្យទិសដៅប្រចាំឆ្នាំបានជ្រួតជ្រាបទៅក្នុងដួងចិត្តអ្នកទាំងអស់គ្នា អាត្មាភាពបាននិយាយនូវសេចក្តីសឹងតែដដែលៗបីឆ្នាំជាប់ៗគ្នាមកហើយ។ឆ្នាំនេះអាត្មាភាពសូមជូនចំណុចថ្មីមួយចំនួនមានពាក្យ ＜ស្មារតី「ទីនេះគឺជាទីកន្លែងប្រត្តិបត្ត」＞បន្ថែម។

អ្នកទាំងអស់គ្នាក៏ជ្រាបហើយដែរថាគឺជាឃ្លាដំបូងគេនៃកណ្ឌព្រះធម៌ពណ៌ខៀវត្រង់

＜ទស្សនៈទៅលើទីកន្លែងប្រត្តិបត្ត＞។បើនិយាយពី＜ទីកន្លែងប្រត្តិបត្ត＞អ្នកទាំងអស់គ្នាតែងតែនឹកដល់ព្រះវិហាធំ ឬព្រះវិហារនានានៅតាមសង្កាត់ដែលអ្នករស់នៅ។ក៏ប៉ុន្តែតាមពិតទៅ＜ទីនេះគឺជាទីកន្លែងប្រត្តិបត្ត＞មានន័យថាទីដែលអ្នករស់នៅឬកន្លែងដែលកំពុងនៅ ទីដែលខ្លួនអ្នកកំពុងឈរ ពោលគឺថាទីណាក៏ដោយក៏ជាព្រះវិហារដែរ។

គេច្រើនតែនិយាយប្រដូចទៅនឹងកីឡាចំបាប់ស៊ឺម៉ុ ។ ព្រះវិហារឬកន្លែងសម្រាប់ប្រត្តិបត្តការសិក្សាព្រះធម៌នៅក្នុងតំបន់ គឺប្រដូចបានទៅនឹងកន្លែងហាត់កីឡាស៊ឺម៉ុ។រីឯសៃវៀនប្រកួតប្រជែងគ្នាប្រៀបប្រដូចទៅនឹងគេហដ្ឋានឬគ្រួសារ កន្លែងធ្វើការ សាលារៀន និងសង្គមរស់នៅ។

នៅក្នុងជីវភាពរស់នៅជារៀងរាល់ថ្ងៃ តែងតែមានហេតុការណ៍ផ្សេងៗកើតឡើង។ដោយសារតែនៅឯណាក៏តែងតែមានមនុស្សអត្តទត្តបុគ្គល,ដើម្បីយោគយល់គ្នាទៅវិញទៅមក ឬក៏អត់ឱនសណ្តោសដើម្បីកុំឱ្យមានវិវាតកើតឡើងនោះមិនមែនជាការងាយស្រួលនឹងធ្វើឡើយ។

នៅពេលដែលយើងជួបប្រទះនឹងមនុស្សដែលមិនត្រូវធាតុជាមួយនឹងយើង ឬក៏ត្រូវគេចោលពាក្យអសុរសមកលើ ឬក៏គេធ្វើជាមិនឃើញមិនអើពើនឹងយើងជាដើមយើងតែងតែឈឺចិត្តមិនសុខមិនសប្បាយក្នុងចិត្តឡើយ។

ក៏ប៉ុន្តែជាតិជាមនុស្ស នៅពេលដែលជួបប្រទះនូវភាពមិនសេរី ឬភាពមិនស្រួលចិត្ត មនុស្សតែងតែចង់ជម្នះនិងរើបំរាស់។ប្រសិនបើគ្មានឧបសគ្គមករារាំងឬសេចក្តីលំបាកអ្វីមួយទេមនុស្សច្បាស់ជាមិនអាចអភិវឌ្ឍខ្លួនឯងឱ្យឡើងទៅលើខ្ពស់បានទេ។

ដូច្នេះតែងតែគិតថានៅពេលដែលជួបទុក្ខលំបាក ត្រូវតែទទួលដោយសុទ្ធចិត្តដោយគិតថា ៖សូមអរគុណដោយបានផ្តល់នូវឧបនិស្ស័យសម្រាប់ឱ្យខ្ញុំបានអភិវឌ្ឍខ្លួនឯងឱ្យបានរីកចំរើន។ ឬក៏កន្លែងនេះហើយដែលខ្ញុំត្រូវខំប្រឹង ហើយខំជម្នះឧបសគ្គឱ្យអស់ពីសមត្ថភាព។នេះហើយដែលហៅថាស្មារតី＜ទីនេះគឺជាទីកន្លែងប្រត្តិបត្ត＞នោះ។

ជាពិសេសចំពោះឧបាសកឧបាសិកាដែលសុំសីលនៅផ្ទះ ត្រូវគិតថារាល់ទង្វើឬហេតុការណ៍ដែលកើតឡើងនៅក្នុងជីវភាពរស់នៅរាល់ថ្ងៃរបស់អ្នកគឺសុទ្ធតែជាការរៀនសូត្រនិងការហាត់ហ្វឹកហ្វឺនចំរើនធម៌ទាំងអស់។គ្មានអ្វីជាពិសេសទេទោះជាថាគ្រាន់តែជួបមនុស្សហើយនិយាយគ្នាលេងធម្មតា ធ្វើការងារនៅក្នុងរោងចក្រឬប៊ុយរ៉ូ ឬលក់ដូរ ឬទៅរៀននៅសាលារៀន,ធ្វើម្ហូបឬបោសជូតសំអាត ។ល។និង។ល។ត្រូវធ្វើដោយហ្មត់ចត់មួយៗមិនធ្វើឱ្យរួចតែពីដៃ ដើម្បីឱ្យក្លាយទៅជាទម្លាប់ល្អចំពោះខ្លួន។ការធ្វើបែបនេះនាំឱ្យកាយនិងចិត្តមានតុល្យភាពល្អ។

ក្នុងចំណោមទីកន្លែងប្រត្តិបត្តទាំងឡាយជាពិសេសគ្រួសារឬផ្ទះសម្បែងគឺជាទីកន្លែងដែលមនុស្សម្នាក់ៗអាចនិយាយឬធ្វើអ្វីតាមចំណង់ចិត្តរបស់ខ្លួនជាងទីណាៗ។ដោយសារតែគិតថាអ្នកផ្ទះជាមនុស្សជិតស្និទ្ធនឹងគ្នាស្គាល់ចិត្តគ្នាច្បាស់ហើយចាំបាច់អីក្រែងរអែងចិត្តគ្នានោះក៏ទៅជាទទួលនូវពាក្យទ្រគោះបោះបោកមិនសមរម្យមកលើក៏មាន។ក្នុងកាលៈទេសៈបែបនេះការទប់ចិត្ត ហើយខំបំភ្លេចអត្តទត្ថៈភាព ប្រត្តិបត្តតាមធម៌ព្រះពុទ្ធគឺជាកិច្ចការលំបាកហួសពីការស្មាន។ដូច្នេះហើយទើបបានជាគេថា គ្រួសារឬផ្ទះសម្បែងគឺជាទីកន្លែងសម្រាប់កកើតឡើងនូវភាពជាមនុស្ស។

នៅជំនាន់អេដូ មានព្រះគ្រូមួយព្រះអង្គជាព្រះសង្ឃខាងនិកាយរីនហៃដំបូង គឺព្រះគ្រូស៊ីដូ ប៊ូណាន់ខាងធ្វើវិប្បសនាហ្សិនលោកបានបន្សល់កំណាព្យបែបម៉ាគាមួយថា៖

ពាក្យថាម៉ាគា អត់មានអ្វីនឹងត្រូវឆ្ងល់ទេ។គឺអ្វីៗដែលអ្នកធ្វើព្រឹកល្ងាចនោះឯង។

មានន័យថា៖មនុស្សជាច្រើនៗគិតថាមាគ៌ានៃព្រះពុទ្ធសាសនាខ្ពង់ខ្ពស់ជ្រុលពេក ពិបាកយល់ណាស់។ក៏ប៉ុន្តែមិនត្រូវបារម្ភនឹងពាក្យនោះទេ។ចូរដឹងថាអ្វីដែលអ្នកធ្វើព្រឹកល្ងាចជាប្រចាំនោះហើយជាមាគ៌ានៃព្រះពុទ្ធសាសនានោះ។ កំណាព្យបែបម៉ាគានេះជាឧទាហរណ៍ដ៏ប្រសើរមួយសម្រាប់បង្ហាញយ៉ាងច្បាស់ពីន័យនៃពាក្យថា ＜ទីនេះជាទីកន្លែងប្រត្តិបត្ត＞នោះ។



## គំនិតដែលចង់រំដោះអ្នកដទៃមុនពេលរំដោះខ្លួនគឺមានសេចក្ដីទុកចិត្តនៅក្នុងមនុស្សគ្រប់គ្នា

ចុះតើអ្វីទៅដែលត្រូវនឹងឬក៏ឆ្លើយតបទៅនឹងធម៌ព្រះពុទ្ធនោះ? អាត្មាភាពនឹងពន្យល់ឱ្យបានក្បោះក្បាយបន្តិច។

រីហ្សូកូសេកៃយើងយកព្រះគម្ពីរបទុមសូត្រមកធ្វើជាគម្ពីរគោល។ ហើយគម្ពីរព្រះបទុមសូត្រនេះបង្រៀនយើងជាអាថ៌ពី＜ឥរិយាបថនៃព្រះពោធិសត្វ＞។

＜ព្រះពោធិសត្វ＞គឺមនុស្សដែលមានចិត្តចង់ត្រាស់ដឹងហើយជាមួយនឹងគ្នានោះដែរចង់ជួយអ្នកដទៃឱ្យរួចចាកផុតពីទុក្ខ។ ទឹកចិត្តល្អដែលទោះជាទៅដល់ណាក៏មិនភ្លេចនោះគេហៅថា＜ឥរិយាបថនៃព្រះពោធិសត្វ＞។និយាយឱ្យស្រួលស្ដាប់ទៅគឺយើងត្រូវរៀនធម៌ព្រះពុទ្ធឱ្យចេះចាំហើយអនុវត្តនូវចិត្តមេត្តាករុណានិងសមានចិត្តចំពោះអ្នកដទៃឱ្យដូចព្រះសម្មាសម្ពុទ្ធលោកធ្វើ។

មានពាក្យទំនៀមមួយចែងថា　＜ទោះខ្លួនឯងឆ្លងមិនទាន់ផុតឱ្យអ្នកដទៃឆ្លងទៅមុនសិន＞។មានន័យថាឱ្យមានសេចក្ដីប្រាថ្នាឱ្យអ្នកដទៃគេត្រាស់ដឹងមុនខ្លួនចុះ។ទង្វើនេះជាទង្វើដែលថ្លៃថ្លាជាងគេទាំងអស់នៅក្នុងចំណោមឥរិយាបទនានានៃព្រះពោធិសត្វ។

យើងម្នាក់ៗតែងតែគិតថាចង់ឱ្យខ្លួនឯងបានស្រោចស្រង់ផុតពីទុក្ខ សិនបើមិនដូច្នេះទេ ទៅរកជួយអ្នកដទៃមិនកើតទេ។អ្នកខ្លះអាចគិតថាគ្រាន់តែរឿងខ្លួនឯងតែមួយសឹងតែវណ្ឌកទៅហើយទៅឱ្យគិតអីដល់រឿងអ្នកផ្សេងនោះ។

ក៏ប៉ុន្តែចិត្តដែលចង់ស្រោចស្រង់អ្នកដទៃជាងរូបខ្លួនឯងមិនមែនទាល់តែខំរៀនសូត្រហ្វឹកហ្វឺនសុំសីលយូរយារលំបាកលំបិនទើបអាចកើតទឹកចិត្តនោះបាននោះឡើយ　នរណាម្នាក់ក៏មានទឹកចិត្តនោះតាំងពីកំណើតមកដែរ។



ប្រសិនបើខ្លួនឯងផ្ទាល់ធ្លាប់លំបាកក្នុងការសម្រេចចិត្តមិនដឹងត្រូវជ្រើសរើសយកផ្លូវណាដើរ ឬក៏ធ្លាប់មានទុក្ខកង្វល់អ្នកនោះក៏នឹងអាចយល់ដឹងពីទុក្ខនិងកង្វល់របស់អ្នកដទៃហើយមានសមានចិត្តចង់ជួយរំលែកទុក្ខកង្វល់នោះដែរហើយ។ ចិត្តថា៖ គួរឱ្យអាណិតណាស់ ចង់ជួយគាត់ណាស់ នឹងកើតឡើងដោយធម្មជាតិ។នៅពេលដែលដុះនូវចិត្តនេះហើយមនុស្សតែងតែភ្លេចគិតរឿងខ្លួនឯងហើយជួយគេមុន។

ជាពិសេសគឺចិត្តមាតា។ប្រសិនបើឃើញកូនធ្លាក់ចូលទៅក្នុងទឹកស្ទឹង ទោះបីជាខ្លួនចេះហែលទឹកឬមិនចេះ អ្នកម្ដាយច្បាស់ជានឹងលោតទឹកទៅជួយស្រង់កូនភ្លាមមិនលែងឡើយ។ជាធម្មតាគេតែងតែគិតថា៖ ខ្លួនឯងមិនចេះហែលទឹកផងតើលោតចូលទឹកទៅជួយកូនម៉េចនឹងកើត? ហេតុតែចង់សង្គ្រោះជីវិតកូនពេកអ្នកម្ដាយអត់មានពេលគិតវែងឆ្ងាយទេ លោកលោតទឹកទៅរកកូនមុនហើយ។

តាមពិតទៅមនុស្សយើងម្នាក់បើមើលតែពីខាងក្រៅទៅឃើញខុសគ្នា ក៏ប៉ុន្តែធាតុពិតនៅក្នុងជម្រៅចិត្តគឺដូចគ្នាតែទាំងអស់ហ្នឹង។នរណាម្នាក់ក៏ចង់រស់នៅឱ្យមានន័យនរណាម្នាក់ក៏មានបំណងចង់មានសុភមង្គលដែរ។ហើយម្នាក់ៗមានបំណងពីក្នុងក្រឡឹបេះដូងថាមិនចង់ឈ្លោះប្រកែកជាមួយនរណាទេ ចង់រស់នៅដោយសុខក្សេមក្សាន្តជាមួយគេជាមួយឯង។

ក៏ប៉ុន្តែប្រសិនបើម្នាក់ៗគ្រាន់តែរស់ដោយបើកមាត់ចំហាផ្លុងឥតគិតអ្វីទេនោះ អ្វីទាំងនេះមិនអាចសម្រេចទៅបានទេ។ដូច្នេះយើងទាំងអស់គ្នាត្រូវតែខំរៀនឱ្យចេះធម៌ព្រះពុទ្ធឱ្យច្បាស់ត្រឹមត្រូវហើយយកមកធ្វើជាគំនិតនៅក្នុងជីវភាពរស់នៅរាល់ថ្ងៃរបស់យើងដោយធ្វើទង្វើដដែលៗឱ្យទៅជាទម្លាប់ជាបាតគ្រឹះនៃរចនាបទរស់នៅរបស់យើង។

មាគ៌ាព្រះពុទ្ធគ្មានកំណត់ព្រំដែនថាចប់ត្រឹមនេះឬត្រឹមនោះទេ។ទោះជាគិតថាចេះធម៌ព្រះបានបន្តិចបន្តួចហើយក្ដីក៏ដោយជួនកាលឱ្យតែមានអីបន្តិចកើតឡើង ក៏តាំង ទៅជាមនុស្សអត្តទត្ថៈបុគ្គលក្រេវក្រោធ ហើយតបប៉ប៉ែសផាំងៗទៅគេទៅឯងវិញជាដើម។នៅពេលបែបនេះយើងត្រូវបែរក្រោយក្រឡេកមើលមកក្នុងខ្លួនឯងវិញម្ដងហើយបណ្ដុះចិត្តថ្មីស្រឡាងមួយ ធ្វើឱ្យជីវិតមួយប៉ប្រិចៗរបស់ខ្លួនមួយថ្ងៃៗមានន័យមានខ្លឹមសារ។នោះហើយជាវិធីព្យាយាមរបស់ពួកយើង។

＜ទីនេះជាទីកន្លែងប្រត្តិបត្ត＞　--គិតជានិច្ចជាកាលថាមានជីវិតរស់នៅគឺមានការតស៊ូរៀនសូត្រ-។ ក្នុងរយៈពេលមួយឆ្នាំទៅមុខនេះចូរយើងព្យាយាមប្រត្តិបត្តឱ្យបានខ្ជាប់ខ្ជួន។

(កាសែតកូសេ លេខ៥ ខែមករា ឆ្នាំ២០២០)

